ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ២៧៥៧ ព.ណ.[illegible]

ថ្ងៃ ច័ន្ទ ០៥ រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ. អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ដល់១៥ ខែសីហា ឆ្នាំ២០១៨ នឹងត្រូវលក់ ៤.១២៣រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៩៣៧រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី០១ ដល់១៥ ខែសីហា ឆ្នាំ២០១៨** នឹងចុះមក ៣.៩៥០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៧៥០ រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) |
|---|---|---|---|
| ១ | **Average MOPS** | 0,៥០៧២ ដុល្លារ | 0,៥៤២២ ដុល្លារ |
| ២ | ពន្ធ៖ | 0,១៧៩១ ដុល្លារ | 0,០៦៩៦ ដុល្លារ |
| | ពន្ធគយ | 0,០៧២៦ ដុល្លារ | 0,0000 ដុល្លារ |
| | អាករបន្ថែម | 0,០២០០ ដុល្លារ | 0,០៤០០ ដុល្លារ |
| | អាករពិសេស | 0,០៨៦៥ ដុល្លារ | 0,០២៩៦ ដុល្លារ |
| ៣ | **PREMIUM** | 0,២០ ដុល្លារ | 0,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | 0,០៨៨៦ ដុល្លារ | 0,០៨៤២ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | 0,៩៧៤៩ ដុល្លារ | 0,៩២៦០ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | ៣.៩៦០ រៀល | ៣.៧៦១ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | 0,៩៧ ដុល្លារ | 0,៩៣ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | ៣.៩៥០ រៀល | ៣.៧៥០ រៀល |

សម្គាល់៖ អាត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨ ដែលស្មើនឹង ៤០៦២រៀល/ដុល្លារអាមេរិក

ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង Gasoil (USD/Barrel) |
|---|---|---|
| ១៦ កក្កដា ២០១៨ | ៨១,៣៤ | ៨៦,២៨ |
| ១៧ កក្កដា ២០១៨ | ៧៧,៧៨ | ៨៣,៧២ |
| ១៨ កក្កដា ២០១៨ | ៧៦,៩៧ | ៨៣,០២ |
| ១៩ កក្កដា ២០១៨ | ៧៨,២៣ | ៨៤,២៣ |
| ២០ កក្កដា ២០១៨ | ៧៩,៦៧ | ៨៥,៦៤ |
| ២៣ កក្កដា ២០១៨ | ៨០,២៧ | ៨៥,៦៧ |
| ២៤ កក្កដា ២០១៨ | ៨០,៩៣ | ៨៦,០៩ |
| ២៥ កក្កដា ២០១៨ | ៨២,១៩ | ៨៧,២៣ |
| ២៦ កក្កដា ២០១៨ | ៨២,៥៧ | ៨៨,៣១ |
| ២៧ កក្កដា ២០១៨ | ៨២,៤១ | ៨៨,៣១ |
| ៣០ កក្កដា ២០១៨ | ៨២,៦៣ | ៨៧,៩៤ |
| ៣១ កក្កដា ២០១៨ | ៨២,៧៨ | ៨៨,០៥ |
| មធ្យមភាគ ១២ថ្ងៃ | ៨០,៦៤៧៥ | ៨៦,២០៧៥ |
| មធ្យមភាគ (ដុល្លារ/លីត្រ) | ០,៥០៧២ | ០,៥៤២២ |

សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការចាំបាច់។